# ព័ត៌មាន: ការទាមទារសំណងពី BP ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០

<u>របៀបដាក់ពាក្យប្ដឹងទាមទារ</u>

**ការដាក់ពាក្យប្ដឹងទាមទារ ធ្វើឡើងដោយឥតគិតថ្លៃ ងាយៗ ហើយមានពីរបីរបៀប:**

- លេខទូរស័ព្ទឥតគិតថ្លៃ សម្រាប់ការទាមទារ គឺ **1-800-440-0858** ។ ខ្សែទូរស័ព្ទនេះបម្រើការ 24 ម៉ោង រៀងរាល់ថ្ងៃ។
- ដាក់ពាក្យប្ដឹងទាមទារតាមប្រព័ន្ធអ៊ីនធើណិត ហើយទទួលបានព័ត៌មានបន្ថែម ពីវែបសាយផ្សេងៗ រាប់ទាំង www.bp.com/claims ។
- ទៅកាន់មជ្ឈមណ្ឌលទាមទាររបស់ BP មួយក្នុងចំណោមមជ្ឈមណ្ឌលជាច្រើន។ ស្វែងរកបញ្ជីមជ្ឈមណ្ឌលទាមទារពី www.bp.com/claims ។
  BP សូមណែនាំដល់អ្នកទាមទារសំណងទាំងអស់ថា ជាដំបូងត្រូវយកលេខទាមទារ ដោយទូរស័ព្ទទៅខ្សែទូរស័ព្ទដែលឥតគិតថ្លៃ។ ការធ្វើដូច្នេះ គឺដើម្បីបញ្ចៀសនូវការពន្យារពេលនានា។
- ផ្ញើការទាមទារនោះ តាមប្រៃសណីយ៍ ទៅកាន់ ESIS, PO BOX 17160, Wilmington, DE 19850 ។

BP កំពុងព្យាយាមធ្វើយ៉ាងណាឱ្យដំណើរការនៃការទាមទារ មានលក្ខណៈសាមញ្ញ តាមដែលអាចធ្វើទៅបាន។

- អ្នកអាចប្ដឹងទាមទារយកប្រាក់ចំណូលដែលបានបាត់បង់ ដោយមានបែបបទកាត់ពន្ធ ឬ W-2 – អ្វីក៏ដោយដែលនឹងបង្ហាញពីប្រាក់ចំណូលពីមុនរបស់អ្នក ក្នុងរយៈពេល 30 ថ្ងៃ។
- អ្នកដែលធ្វើការលើនាវា ឬកប៉ាល់ និងអ្នកដទៃទៀត ដែលទទួលបានថ្លៃឈ្នួលជាសាច់ប្រាក់សុទ្ធ ក៏អាចទាមទារសំណងបានដែរ។ សូមផ្ដល់អត្តសញ្ញាណប័ណ្ណដែលមានរូបថត និងប័ណ្ណបើកប្រាក់ ឬឯកសារដទៃទៀតដែលបង្ហាញពីចំនួនទឹកប្រាក់ ដែលអ្នករកបាន។ សូមផ្ដល់លេខទូរស័ព្ទរបស់កាពីតែននាវា ឬកប៉ាល់ ឬអ្នកគ្រប់គ្រង ដើម្បីធ្វើការបញ្ជាក់ពីការងាររបស់អ្នក។
- BP នឹងបន្តធ្វើការវាយតំលៃ មិនថាមានការសមរម្យចំពោះប្រាក់សំណងបន្ថែម ឬក៏អត់ទេ ពីព្រោះអ្នកមិនអាចចូលទៅបំពេញការងារបាន ដោយសារតែការកំពប់ប្រេងនេះ។
- អ្នកគួរតែដាក់ពាក្យប្ដឹងទាមទារ តែមួយប៉ុណ្ណោះ។ អ្នកអាចរាយការណ៍ប្រភេទផ្សេងៗនៃការខូចខាតនៅលើបែបបទតែមួយ ដែលមានលេខទាមទារដូចគ្នា។ លេខទាមទារច្រើន នឹងពន្យារដល់ការពិនិត្យមើលនៃការទាមទារ។ អ្នកវាយតំលៃអំពីការទាមទារ នឹងជួយដោះស្រាយនូវករណីលើកលែងទាំងឡាយ ចំពោះការទាមទារនេះ។
- សូមពិភាក្សាសំណួររបស់អ្នកជាមួយអ្នកវាយតំលៃអំពីការទាមទារ។

<u>ឯកសារគាំទ្រ</u>

សូមផ្ដល់អត្តសញ្ញាណប័ណ្ណដែលមានរូបថត និងឯកសារផ្សេងៗ ដើម្បីគាំទ្រការបាត់បង់របស់អ្នក។ ឯកសារបន្ថែម ដែលប្រហែលជាគេត្រូវការ ដើម្បីគាំទ្រការទាមទាររបស់អ្នក:

- ការទាមទារការបាត់បង់ប្រាក់ចំណូល ឬ ប្រាក់ចំណេញសុទ្ធ: អាចមានសៀវភៅបង់ពន្ធ សំបុត្រធ្វើដំណើរ របាយការណ៍ខាតប្រាក់ឈ្នួល ប័ណ្ណដាក់ប្រាក់ ការចុះបញ្ជីទូក ឬច្បាប់ចម្លងនៃអាជ្ញាប័ណ្ណនេសាទបច្ចុប្បន្ន។

- ការទាមទារការបាត់បង់ខាងសេដ្ឋកិច្ចពាណិជ្ជកម្ម: អាចតម្រូវឱ្យមាននូវកំណត់ត្រាជាក់លាក់បន្ថែមពីក្រុមហ៊ុន។
- ការទាមទារពីការបាត់បង់ថ្លៃឈ្នួល: អាចមានអត្រាតាំងទីលំនៅមុនកើតហេតុ ការលុបចោល សៀវភៅពន្ធ និង សៀវភៅគណនេយ្យ។
- ការទាមទារពីការខូចខាតទ្រព្យសម្បត្តិ: អាចតម្រូវឱ្យមានរូបថត និងបង្កាន់ដៃជួសជុល ឬសំអាត។ ការទាមទារការខូចខាតទ្រព្យសម្បត្តិធំៗ ប្រហែលជាអាចតម្រូវឱ្យមានការចុះទៅពិនិត្យដល់កន្លែងដោយអ្នកវាយតំលៃ។
- ការទាមទារសំណងរបួសស្នាមខាងរាងកាយ: មិនមានការទូទាត់ឱ្យឡើយ ក្រោមច្បាប់បំពុលប្រេង ឆ្នាំ 1990; ប៉ុន្តែ BP នឹងធ្វើការវាយតំលៃអំពីការទាមទារសំណងរបួសស្នាមខាងរាងកាយនិមួយៗ ដែលបានបញ្ជូនមក តាមករណីជាក់ស្តែងនិមួយៗ។ អ្នកនឹងត្រូវផ្តល់នូវសៀវភៅពេទ្យ វិក្កយបត្រពេទ្យ កំណត់ត្រារបស់ហ្វាម៉ាស៊ី ដើម្បីគាំទ្រដល់ការទាមទារនេះ។

<u>របៀបពិនិត្យមើលការទាមទារដែលមានរួចហើយ</u>

ដើម្បីពិនិត្យមើលពីស្ថានភាពនៃការទាមទារ ឬបើសិនជាអ្នកមិនបានទទួលដំណឹងពីអ្នកវាយតំលៃទេ សូមទូរស័ព្ទមកលេខ **1-800-573-8249** ចន្លោះពីម៉ោង 9 ព្រឹក និង 9 ល្ងាច ម៉ោងនៅ EDT រៀងរាល់ថ្ងៃ។ សូមត្រៀមលក្ខណៈក្នុងការផ្តល់ឈ្មោះ អាសយដ្ឋាន និងលេខទាមទាររបស់អ្នក។

**មិនមានបុគ្គល ដែលអះអាងពីការទាមទារ ឬទទួលបានសំណងសម្រាប់អត្ថប្រយោជន៍បណ្តោះអាសន្នណាម្នាក់ នឹងត្រូវបានគេស្នើសុំ ឬតម្រូវឱ្យចុះហត្ថលេខាលើការផ្សព្វផ្សាយព័ត៌មានណាមួយ ឬបោះបង់សិទ្ធិណាមួយក្នុងការអះអាងអំពីការទាមទារបន្ថែម ដើម្បីមក ប្តឹងជាឯកត្តបុគ្គល ឬចូលរួមក្នុងសកម្មភាពផ្លូវច្បាប់ដទៃទៀត ដែលពាក់ព័ន្ធនឹងឧប្បត្តិហេតុលិចប្រេងនៅបាតសមុទ្រនេះឡើយ។**